# ពាក្យ "ចារឹក ស្លឹករឹត និងគម្ពីរ"

នាពេលបច្ចុប្បន្ននេះ យើងយល់ថាពាក្យ **ចារឹក** ជាពាក្យតែមួយម៉ាត់ ប៉ុន្តែបើមើលឱ្យវែងឆ្ងាយបន្តិច នោះនឹងឃើញថាកើតមកពីពាក្យពីរផ្សំគ្នា។ ន័យបច្ចុប្បន្នរបស់ពាក្យ **ចារឹក** គឺចារ សរសេរ ឬកត់ ប៉ុន្តែបើយើងមើលអ្វីដែលគេចារឹករួចហើយ ដូចជាគោលចារឹក ផ្ទាំងចារឹក សិលាចារឹកជាដើមនោះ សុទ្ធតែកើតដោយដែកចារ ឬដាប់ផ្ទៃឱ្យខូងជ្រៅពុំគ្រាន់តែសរសេរធម្មតាដោយប្រើប៊ិក ឬខ្មៅដៃនោះទេ។ ពាក្យ **ចារឹក** កើតមកពីពាក្យ **ចារ** និង **រឹក**។ ពាក្យ **ចារ** យើងយល់ដោយងាយរួចហើយ។ ឯ **រឹក** ជាពាក្យមកពីសំស្ក្រឹតថា **រិក្ត**[១] (បើអានតាមមាត់ខ្មែរឥឡូវថា **រឹក**) មានន័យថាផ្ទៃទទេស្អាត[២] គឺសំដៅដល់ផ្ទាំងថ្ម លោហៈ ស្លឹករុក្ខជាតិជាដើម ដែលគេបានសម្អាតផ្ទៃឱ្យស្អាត ហើយប្រើសម្រាប់ចារអត្ថបទអ្វីមួយ។ ពាក្យនេះជួបច្រើនក្នុងសិលាចារឹកខ្មែរបុរាណដូចជា៖ **ទុក្តវ្រះរិក្ត** (K.598B:45) = ចារលើ**ព្រះរិក្ត**, **ទុក្តវ្រះរិក្តបិទុក៌នាកម្រតេងជគតគ្រឹគិខរិគ្វរ** (K.380W:20) = ចារលើ**ព្រះរិក្ត**ដើម្បីទុកនៅប្រាសាទ**ស្រីសិខរិស្វរ**(ប្រាសាទព្រះវិហារ)។ល។



ទុក្តវ្រះរិក្តបិទុក៌នាកម្រតេងជគតគ្រឹគិខរិគ្វរ

អត្ថបទស្រង់ចាកសិលាចារឹកប្រាសាទព្រះវិហារ K.380W

ចំណែកពាក្យ **ស្លឹករឹត** មកពីពាក្យ **ស្លឹក** និង**រឹត**។ **ស្លឹក** ទីនេះ សំដៅដល់ស្លឹកទ្រាំង ដែលគេកាប់យកកំពូលមកធ្វើតាមលំដាប់លំដោយ ដើម្បីបានជាសន្លឹកដែលនឹងប្រើសម្រាប់ចារអក្សរលើនោះបាន។ **រឹត** ជាសំណេរក្លាយពីបាលី **រិត្ត** ដែលត្រូវនឹងពាក្យសំស្ក្រឹតថា **រិក្ត** ដូចបានបង្ហាញខាងលើរួចហើយ។ នៅពេលដែលគេចារអក្សរលើនោះ គេលែងហៅថា **ស្លឹករឹត** ទៀតហើយ ហៅថា **សាស្ត្រា** ឬ **វ៉ាន** (សាស្ត្រាក្បួន ប្រវែងខ្លីជាងសាស្ត្រាទូទៅ) វិញ។

[១] នៅក្នុងសិលាចារឹកមានសំណេរជា **រិក្ត** និង **រិក៌**(សំណេរបែបខ្មែរក្លាយពីពាក្យសំស្ក្រឹត **រិក្ត**)។

[២] Pou 2004 : 403.

អត្ថបទដោយ៖ លោក ហ៊ុន ឈុនតេង

នៅក្នុងអត្ថបទសិលាចារឹកសំស្រ្កឹតហៅ **ស៊ឹករឹត** នេះថា **វិក្តបត្រ** (K.290D:6)។ **បត្រ** ជាពាក្យសំស្រ្កឹតមានន័យថា ស៊ឹក សន្លឹក។ ដូច្នេះ **វិក្តបត្រ** មានន័យថា **ស៊ឹករឹត** នេះឯង។


វិក្តបត្រំ

វិក្តបត្រំ = ស៊ឹករឹត (ស្រង់ចាកសិលាចារឹកទេពប្រណម្យ K.290)

នៅក្នុងវចនានុក្រមខ្មែរពន្យល់ពាក្យ **គម្ពីរ** ថាមានប្រភពមកពីពាក្យក្លាយមកពីបាលីថា **គម្ភីរ** មានន័យថាជ្រៅ គឺសំដៅដល់សាស្រ្តា ច្បាប់ ធម្មវិន័យ ដែលរួបរួមដោយពួកដោយប៉ែក ដោយខ្សែ[៣]។ សិលាចារឹកភាសាខ្មែរសរសេរពាក្យនេះជា **កំវិ** ឬ **កំវី** ក្រោយមកក្លាយជា **កំពី**។ **កំវិ** ឬ **កំវី** ជាពាក្យខ្មែរបុរាណដែលកម្លាយមកពីពាក្យ **វី** ត្រូវនឹងពាក្យខ្មែរទំនើបថា **ពី** ដូចពាក្យថា **ពីនេះពីនោះ** គឺសំដៅដល់រឿងនេះផង រឿងនោះផងជាដើម។ ពាក្យ **វី** នេះបង្កើតបានជាពាក្យ **អ្វី** និង **អំវិ** ឬ**អំវី**(អំពី) ដែលពាក្យទាំងពីនេះសុទ្ធតែបញ្ជាក់ពីរឿង ឬហេតុការណ៍អ្វីមួយ[៤]។ យើងឃើញថា **កំវី** ច្រើនតែកត់ត្រារឿងរ៉ាវសំខាន់នានាដែលភាគច្រើនជាការត្រាស់បង្គាប់របស់ព្រះរាជាផង។ ក្នុងសិលាចារឹកថ្មីមួយរកឃើញនៅស្រុកបរវេល ខេត្តបាត់ដំបង ព្រះមហាក្សត្របានត្រាស់បង្គាប់ឱ្យគេចារគម្ពីរមាសដាក់នៅកន្ទោងព្រះ(ប្រាសាទ)ដូចមានឃ្លាថា **វ្រះប្រេទុក្តវ្រះវិក្តកំវិមាសអាយិកន្ទោងវ្រះ** មានន័យថាព្រះមហាក្សត្រត្រាស់ឱ្យចារព្រះវិក្តគម្ពីរមាសទុកនៅកន្ទោងព្រះ។


វ្រះប្រេទុក្តវ្រះវិក្តកំវិមាសអាយិកន្ទោងវ្រះ

អត្ថបទដកស្រង់ពីសិលាចារឹករកឃើញនៅឃុំព្រៃខ្ពស់ ស្រុកបរវេល

[៣] វចនានុក្រមខ្មែរ ភាគ១ ១៩៦៧ : ១៣០។

[៤] សូមអានបន្ថែម ឃីង ហុកឌី ២០០៣: ២៥-២៧។

អត្ថបទដោយ៖ លោក ហ៊ុន ឈុនតេង

## *ឯកសារយោង*

*ឃីង ហុកឌី*

២០០៣. *ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ*, បណ្ណាគារអង្គរ, ភ្នំពេញ។

*ពុទ្ធសាសនបណ្ឌិត្យ*

១៩៦៧. *វចនានុក្រមខ្មែរភាគ១*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

Pou, Saveros.

2004. *Dictionnaire Vieux Khmer – Français – Anglais*, L'harmattan.